01182497

E370/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 12 / 2015
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥

ផ្ញើជូន៖ ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ៖ សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឲ្យពន្លឿនការកោះហៅសាក្សីពីររូបដែលបានស្នើសុំរួចហើយ និងសុំឲ្យកោះហៅសាក្សីបន្ថែមនៅក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះក្រុមគោលដៅជាក់លាក់ ជនជាតិចាម (សំអាងហេតុពេញលេញនឹងចេញនៅពេលក្រោយ)

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរួមមួយដែលបានដាក់នៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ដោយមេធាវីការពារក្តី នួន ជា បានស្នើសុំដល់អង្គជំនុំជម្រះឲ្យពន្លឿនការចេញសេចក្តីសម្រេចកោះហៅសាក្សីដែលមានរហស្សនាម 2-TCW-831 និង 2-TCW-951 អនុលោមតាមវិធាន ៩១ និងស្នើសុំកោះហៅសាក្សីបន្ថែម គឺ សម្តេច ហ៊ុន សែន (2-TCW-1001) សូ ស៊ីម៉ិច (2-TCW-997) កា ដេវ (2-TCW-998) និង 2-TCW-917 ដើម្បីផ្តល់សក្ខីកម្មអនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) ក្នុងអំឡុងពេលសវនាការលើអង្គហេតុស្តីពីការ

ប្រព្រឹត្តិចំពោះជនជាតិចាម (ឯកសារ E370 កថាខណ្ឌ ១)។ នៅក្នុងសារណាតបដែលបានដាក់ដាច់ដោយឡែកពីគ្នា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានជំទាស់ទៅនឹងការកោះហៅសាក្សីនានាក្នុងចំណោមសាក្សីទាំងនេះទេ (ឯកសារ E370/1 កថាខណ្ឌ ២, ៤ ដល់ ៦) ចំណែកសហព្រះរាជអាជ្ញាជាតិជំទាស់ទៅនឹងការកោះហៅសាក្សីដែលមានរហស្សនាម 2-TCW-831, 2-TCW-951 និង សម្តេច ហ៊ុន សែន (2-TCW-1001) (ឯកសារ E370/2 កថាខណ្ឌ ២, ១០)។

២. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេច៖

ក) <u>បដិសេធ</u> សំណើសុំកោះហៅ សម្តេច ហ៊ុន សែន (2-TCW-1001), ស្វ សីម៉ិច (2-TCW-997), និង កា ដេវ (2-TCW-998) ដើម្បីមកផ្តល់សក្ខីកម្មចំពោះអង្គហេតុនៃការប្រព្រឹត្តិចំពោះក្រុមគោលដៅជាក់លាក់ ជនជាតិចាម។

ខ) <u>ពន្យារ</u> ការសម្រេចទៅលើសំណើសុំស្តាប់សក្ខីកម្មសាក្សី 2-TCW-831, 2-TCW-951 និង 2-TCW-917 នៅពេលសមស្របណាមួយក្នុងអំឡុងកិច្ចដំណើការនីតិវិធីខាងមុខ។

៣. សេចក្តីសម្រេចដែលមានសំអាងហេតុពេញលេញនឹងចេញនៅពេលសមស្របខាងមុខ។